ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Nov-2015, 15:44
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខៈ**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារៈ** ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥
**ភាសាដើមៈ** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារៈ** សាធារណៈ

---

# ដីកាកំណត់កាលវិភាគសវនាការសម្រាប់សវនាការបណ្ដឹងសាទុក្ខ និងការជូនដំណឹងភាគីអំពីបញ្ហាដែលត្រូវលើកឡើង

---

**សហព្រះរាជអាជ្ញា**

**សហមេធាវីជនជាប់ចោទ នួន ជា**

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F30/4

ជា លាង

Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

សុន អរុណ

Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**")

**កត់សម្គាល់**លើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ("សាលក្រម") ដែលបានចេញនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤[1],

**បានទទួល** បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែលធ្វើឡើងដោយ សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន[2],

**រំលឹក**ថា នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូល បានចេញដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹង[3] *ក្នុងចំណោមនោះ* បានបង្គាប់ថា សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក នឹងធ្វើឡើងនៅថ្ងៃ ច័ន្ទ ទី ១៦ ដល់ថ្ងៃ ពុធ ទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ដែលជាថ្ងៃបម្រុង និងភ្ជាប់មកជាមួយកាលវិភាគបណ្តោះអាសន្ន សម្រាប់សវនាការ ដោយបានស្នើឱ្យភាគីដាក់សេចក្តីសង្កេតរបស់ខ្លួនលើកាលវិភាគនេះ,

**កត់សម្គាល់**"សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើកាលវិភាគសម្រាប់សវនាការ នៃសំណុំរឿង ០០២/០១"[4] ក្នុងនោះ សហព្រះរាជអាជ្ញា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល បង្កើនពេលវេលាពី ៣៥ ទៅ ៨០ នាទី សម្រាប់សារណាស្តីពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់

---

[1] សាលក្រមនៃសំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313។

[2] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ F11។ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F16។ *[កែតម្រូវលើកទី ១] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១* ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F17 (សំណៅដែលត្រូវបានកែតម្រូវ ត្រូវបានដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤)។ សូមមើលផងដែរ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/3/1។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/1/1។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/2/1។

[3] ឯកសារលេខ F30។

[4] ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F30/1 ("សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា")។

ចោទ និង ពី ២៥ ទៅ ៦០ នាទី សម្រាប់ឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាព ដោយបាន លើកឡើង *ក្នុងចំណោមនោះ* ថា ទស្សនៈទ្រឹស្តីនៃបណ្តឹងសាទុក្ខទាក់ទងនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ និងឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាព បានលើកឡើងនូវបញ្ហាស្មុគស្មាញផ្នែកអង្គហេតុ និងច្បាប់យ៉ាងច្រើន និងថា មានភាពត្រួតគ្នាបន្តិចបន្តួចប៉ុណ្ណោះរវាងទស្សនៈទ្រឹស្តីនៃបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន និងថា ការផ្តល់ឱ្យសហព្រះរាជអាជ្ញានូវពេលវេលាតិចជាងជនជាប់ចោទក្នុងការធ្វើសារណាផ្ទាល់មាត់ អាចប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងធ្វើឱ្យមតិសាធារណជនមានការភាន់ច្រឡំអំពីភស្តុតាង និងបញ្ហានានាដែលកើតឡើងនៅក្នុងរឿងក្តីនេះ[5],

**កត់សម្គាល់**លើ"*សេចក្តីសង្កេតរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាលវិភាគនៃសវនាការបណ្តឹងសាទុក្ខ*"[6] ក្នុងនោះ ខៀវ សំផន បានស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលបង្កើនពេលវេលាពី ៥០ ទៅ ៦៥ នាទី សម្រាប់សារណាស្តីពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដោយផ្អែកលើអំណះអំណាងថា សារណាជាលាយលក្ខណ៍អក្សរលើបណ្តឹងសាទុក្ខ ៧១ ភាគរយ(%) គឺផ្តោតលើបញ្ហានេះ និងថា គាត់ នឹងត្រូវដោះស្រាយលើបញ្ហានៃការកំណត់ប្រភេទបទល្មើសឡើងវិញ នៅក្នុងអំឡុងពេលដែលបានផ្តល់ឱ្យនោះផងដែរ[7],

**កត់សម្គាល់**លើការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងការសង្កេតរបស់សហព្រះរាជអាជ្ញា[8] ដែលក្នុងនោះរំលឹកពីភាពខុសគ្នាជាមូលដ្ឋានរវាងតួនាទីនីមួយៗរបស់ម្ចាស់បណ្តឹងសាទុក្ខ និងអ្នកឆ្លើយតបនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ គាត់ បានយល់ស្របទៅនឹងការបែងចែកពេលវេលានៅក្នុងកាលវិភាគបណ្តោះអាសន្ន ដែលបានកំណត់ដោយអង្គជំនុំជម្រះ ដូចនេះ វាផ្ទុយពីសំណើរបស់សហព្រះរាជអាជ្ញាដែលសុំពេលវេលាបន្ថែម[9] និងស្នើឡើងថា ប្រសិនបើសហព្រះរាជអាជ្ញា ត្រូវបានផ្តល់ពេលវេលាបន្ថែម

---

[5] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២ ដល់ ១៤។

[6] ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F30/2 ("សេចក្តីសង្កេតរបស់ ខៀវ សំផន")។

[7] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៤ ដល់ ៧។

[8] ការឆ្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងកាលវិភាគសវនាការបណ្តឹងសាទុក្ខ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F30/3 ("ការឆ្លើយតបរបស់ ខៀវ សំផន")។

[9] ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៤។

ការបង្កើនពេលវេលានោះ គប្បីត្រូវបានផ្ដល់ឱ្យមានលក្ខណៈសមាមាត្រដល់ក្រុមមេធាវីការពារក្ដីទាំងពីរផងដែរ[10],

**ពិចារណាឃើញ**ថា គោលបំណងនៃសវនាការបណ្ដឹងសាទុក្ខនេះ គឺពុំមែនដើម្បីហាត់សមទឡ្ហីករណ៍ដែលបានលើកឡើងដោយភាគីកន្លងមកនៅក្នុងសារណាជាលាយលក្ខណ៍អក្សរនោះឡើយ ប៉ុន្តែ ជាចម្បង គឺដើម្បីផ្ដល់ឱកាសឱ្យភាគីក្នុងការឆ្លើយតបទៅនឹងសារណាតបរបស់ភាគីដទៃទៀត និងឆ្លើយនូវសំណួររបស់អង្គជំនុំជម្រះតុលាការកំពូល និងថា អាស្រ័យហេតុនេះ ពុំមានហេតុផលអ្វីដែលត្រូវផ្ដល់ឱ្យសហព្រះរាជអាជ្ញានូវពេលវេលាដូចគ្នាទៅនឹង នួន ជា និង ខៀវ សំផន ក្នុងការធ្វើសារណារបស់ខ្លួនឡើយ,

**ពិចារណាឃើញ**ថា ទោះបីជាយ៉ាងណាក៏ដោយ អំណះអំណាងរបស់សហព្រះរាជអាជ្ញាអំពីការត្រួតគ្នាបន្តិចបន្តួចរវាងសារណារបស់ នួន ជា និង ខៀវ សំផន ដែលពុំដូចគ្នាទៅនឹងអំណះអំណាងដែលផ្អែកលើស្ថានភាពសាធារណៈនៃកិច្ចដំណើរការនីតិវិធី និងមតិសាធារណៈនោះ បានធ្វើយុត្តិកម្មដល់ការបង្កើនពេលវេលាដោយមានកម្រិត ដែលបានផ្ដល់ឱ្យសហព្រះរាជអាជ្ញា ក្នុងការធ្វើសារណារបស់ខ្លួនស្ដីពីទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ រួមទាំងឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាព ដូចបានកំណត់នៅក្នុងកាលវិភាគដែលបានភ្ជាប់មកជាមួយនោះ,

**ពិចារណាឃើញ**ថា អំណះអំណាងរបស់ ខៀវ សំផន ក្នុងការគាំទ្រការបង្កើនពេលវេលាសម្រាប់សារណារបស់ខ្លួនលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនោះ ត្រូវបានយកមកពិចារណាយ៉ាងពេញលេញនៅពេលបែងចែកពេលវេលានៅក្នុងកាលវិភាគបណ្ដោះអាសន្ន ទាក់ទងនឹងការអះអាងដែលថា ការបង្កើនពេលវេលាឱ្យទៅសហព្រះរាជអាជ្ញា តម្រូវឱ្យមានការបង្កើនពេលវេលាស្មើគ្នាដល់ក្រុមមេធាវីការពារក្ដី អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ជាថ្មីម្ដងទៀតថា សំណើសុំបន្ថែមនេះ ត្រូវតែបង្ហាញពីអត្ថិភាពនៃ“ផលប្រយោជន៍ផ្លូវច្បាប់ច្បាស់លាស់” ដែលត្រូវការពេលវេលាបន្ថែម និងពុំគ្រាន់តែផ្អែកលើ

---

[10] ការឆ្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៥ ដល់ ៦។

សំណើរបស់ភាគីដទៃទៀតដែលសុំបន្ថែមពេលវេលា និងលទ្ធផលពាក់ព័ន្ធនោះទេ[11] និងថា អាស្រ័យហេតុនេះ ពុំចាំបាច់ធ្វើការកែប្រែកាលវិភាគពាក់ព័ន្ធនឹងបញ្ហានេះទេ,

**ពិចារណាឃើញថា** នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ប្រសិនបើឃើញថា នៅក្នុងអំឡុងពេលនៃសវនាការ ភាគីត្រូវការពេលវេលាបន្ថែមសម្រាប់ការតវ៉ាក្តីរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលមានឆន្ទានុសិទ្ធិផ្តល់ឱកាសឱ្យភាគីដែលស្នើសុំ ក្នុងអំឡុងពេលដែលអង្គជំនុំជម្រះ បម្រុងទុកសម្រាប់សួរសំណួរ,

**ពិចារណាឃើញថា** ដើម្បីជាប្រយោជន៍ក្នុងការរៀបចំសវនាការលើបណ្តឹងសាទុក្ខឱ្យមានប្រសិទ្ធភាពគឺចាំបាច់ត្រូវជូនដំណឹងដល់ភាគីអំពីបញ្ហាដែលអង្គជំនុំជម្រះតុលាការកំពូល បានស្នើឱ្យភាគីធ្វើសារណា នៅក្នុងអំឡុងពេលនោះ និងតាមពេលវេលាដែលបានផ្តល់ជូន,

**បញ្ជាក់ថា** អង្គជំនុំជម្រះតុលាការកំពូល អាចចោទជាសំណួរបន្ថែមដល់ភាគីនៅក្នុងអំឡុងពេលនៃសវនាការ,

**ពិចារណាឃើញថា** សម្រាប់ហេតុផលសម្ភារ ជាការប្រសើរដែលសវនាការបណ្តឹងសាទុក្ខ ត្រូវបានលើកមួយថ្ងៃទៅថ្ងៃបន្ទាប់ ប៉ុន្តែពុំតម្រូវឱ្យមានថ្ងៃបម្រុងទៀតឡើយ,

**ពិចារណាឃើញថា** ដើម្បីជាប្រយោជន៍នៃការរៀបចំឱ្យបានល្អប្រសើរសម្រាប់សវនាការបណ្តឹងសាទុក្ខ ភាគីត្រូវដាក់ឱ្យបានមុនពេលចាប់ផ្តើមនូវបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលខ្លួនមានបំណងផ្អែកលើនៅពេលសវនាការបណ្តឹងសាទុក្ខនេះ រួមទាំងមូលដ្ឋានសំអាង ដូចបានបញ្ជាក់ខាងក្រោម,

## អាស្រ័យហេតុនេះសម្រេច៖

**បង្គាប់ថា** សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក ដោយអនុលោមតាមវិធាន ១០៩ នៃវិធានផ្ទៃក្នុង ត្រូវធ្វើឡើងនៅថ្ងៃ អង្គារ ទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ វេលាម៉ោង ០៩:០០ ព្រឹក នៅក្នុងសាលសវនានៃ អ.វ.ត.ក និងបន្តនៅថ្ងៃ ពុធ ទី ១៨ និងព្រហស្បតិ៍ ទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥,

---

[11] *សូមមើល*សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រសម្រាប់សារណាតបខាងមុខទៅនឹងសំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/8/2/1 ទំព័រ ៣ និង ការយោងត្រូវបានដកស្រង់នៅទីនោះ។

**ទទួលយក**ផ្នែកខ្លះនៃសំណើរបស់សហព្រះរាជអាជ្ញាសុំពេលវេលាបន្ថែម ដើម្បីធ្វើសារណារបស់ខ្លួននៅក្នុងសវនាការបណ្តឹងសាទុក្ខ,

**បដិសេធ** សំណើរបស់ ខៀវ សំផន សុំពេលវេលាបន្ថែមដើម្បីធ្វើសារណានៅក្នុងបណ្តឹងសាទុក្ខ,

**ភ្ជាប់មកជាមួយ**នូវកាលវិភាគសម្រាប់សវនាការ[12],

**ស្នើឱ្យ**ភាគីដោះស្រាយនៅក្នុងសារណា និងតាមពេលវេលាដែលបានផ្តល់ជូននៅក្នុងវគ្គនីមួយៗនៃសវនាការបណ្តឹងសាទុក្ខ នូវបញ្ហាដូចខាងក្រោម៖

*១. នៅក្នុងវគ្គស្តីពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាព:*

- ថាតើ តាមច្បាប់ទម្លាប់អន្តរជាតិដែលមាននៅក្នុងឆ្នាំ ១៩៧៥ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម (ដែលផ្ទុយគ្នាទៅនឹងទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ) ដែរ ឬយ៉ាងណា,
- ថាតើ យោងតាមអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តយ៉ាងពិសេសទៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរ*ដែលអស់លទ្ធភាពក្នុងការប្រយុទ្ធ* ឧក្រិដ្ឋកម្មទាំងនេះ ទោះជាយ៉ាងណាក្តី ត្រូវបានប្រព្រឹត្តឡើង ដែលជាផ្នែកមួយនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល ដែរ ឬយ៉ាងណា,
- ថាតើ ការដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាល(ដែលរួមបញ្ចូលអំពើមនុស្សឃាត) តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូង មានការជឿជាក់ហួសពីវិមតិសង្ស័យទៅលើអំពើមនុស្សឃាតខុសច្បាប់នីមួយៗ ឬជាជម្រើស មានការជឿជាក់ហួសពីវិមតិសង្ស័យទៅលើការកើតឡើងនៃអំពើមនុស្សឃាតខុសច្បាប់ដែលបានផ្អែកទៅលើភស្តុតាងទាំងមូល ដែ ឬយ៉ាងណា,

*២. នៅក្នុងវគ្គស្តីពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាក់ទងនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ:*

---

[12] ឧបសម្ព័ន្ធ ក–កាលវិភាគស្តាពរសម្រាប់សវនាការ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/4.1។

- ថាតើ តាមច្បាប់ទម្លាប់អន្តរជាតិដែលមាននៅក្នុងឆ្នាំ ១៩៧៥ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលផ្អែកលើសហឧក្រិដ្ឋកម្មរួមនៅក្នុងទម្រង់ជាមូលដ្ឋានរបស់ខ្លួន (សន្មតថា សហឧក្រិដ្ឋកម្មរួម នេះ មាននៅក្នុងពេលនោះ) បានតម្រូវយ៉ាងចាំបាច់ថា ចារីត្រូវតែស្នើឡើងថា ឧក្រិដ្ឋកម្មដែល បានចោទប្រកាន់នោះ ត្រូវតែបានប្រព្រឹត្តឡើងតាមរយៈការអនុវត្តនូវគោលបំណងរួម (មានន័យ ថា ការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម គឺជាគោលដៅនៃគោលបំណងរួម) ដែរ ឬយ៉ាងណា ឬថាតើ ការ ទទួលខុសត្រូវនេះ គ្របដណ្តប់ផងដែរ លើស្ថានការណ៍ដែលក្នុងនោះ ចារីបានដឹងថា តាមការ ប្រព្រឹត្តទៅជាធម្មតានៃព្រឹត្តិការណ៍ ឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ (ក) នឹងត្រូវបាន ឬ (ខ) អាចនឹងត្រូវបានប្រព្រឹត្តឡើងនៅក្នុងពេលអនុវត្តនូវគោលបំណងរួម ដែរ ឬយ៉ាងណា,

*៣. នៅក្នុងវគ្គស្តីពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា:*

- ថាតើ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលផ្អែកលើសហឧក្រិដ្ឋកម្មរួមនៅក្នុងទម្រង់ដែលសហ ព្រះរាជអាជ្ញាបានលើកឡើងនោះ រួមបញ្ចូលតែឧក្រិដ្ឋកម្ម ដែលចារីពិតជាបានដឹងជាមុនថាជា អំពីបទល្មើសតែប៉ុណ្ណោះ ឬរួមបញ្ចូលផងដែរនូវឧក្រិដ្ឋកម្មទាំងនោះ ដែលគ្រាន់តែអាចយល់ដឹង ជាមុនបានថាជាអំពីបទល្មើស ដែរ ឬយ៉ាងណា,

**បង្គាប់**ថា ភាគីត្រូវដាក់យ៉ាងយូរបំផុតត្រឹមថ្ងៃ សុក្រ ទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ នូវបញ្ជីមូលដ្ឋានសំអាង ផ្លូវច្បាប់ ដែលខ្លួនមានបំណងផ្អែកលើនៅក្នុងសវនាការលើបណ្តឹងសាទុក្ខ និងដោយស្របតាមមាត្រា ៦ នៃ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[13]មូលដ្ឋានសំអាងផ្លូវច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**

[13] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ អ.វ.ត.ក/០១/២០០៧/វិ.ទី៨ ("សេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ")។